# អត្ថបទផ្សព្វផ្សាយសារព័ត៌មាន

*ថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៨*

*"ប្រទេសកម្ពុជា ត្រូវការគ្រូបង្រៀនច្រើននាក់បន្ថែម និងមានគុណភាពខ្ពស់ឡើងទៀត"*
*តាមខ្លឹមសារនៃ ឯកសារពិភាក្សាមួយរបស់វិទ្យាស្ថាន CDRI*

ឯកសារពិភាក្សាមួយក្រោមចំណងជើងថា "កង្វះខាតជំនាញនៅកម្ពុជា៖ ការវិភាគពីបញ្ហាចោទ និងជម្រើសគោលនយោបាយ" ដែលចេញផ្សាយដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានវែកញែកថា "កង្វះគ្រូបង្រៀននៅគ្រប់កម្រិតនៃវិស័យអប់រំ និងជាពិសេសនៅកម្រិតបឋមសិក្សា គឺជាឧបសគ្គចម្បងដែលរារាំងដល់ការកាត់បន្ថយកង្វះជំនាញនៅកម្ពុជា"។

ឯកសារចេញផ្សាយនៅថ្ងៃនេះ ជា "ឯកសារដំបូងនៃកម្រងការសិក្សាស្រាវជ្រាវផ្នែកគោលនយោបាយ ដែល CDRI គ្រោងអនុវត្តឡើងជាផ្នែកមួយនៃកម្មវិធីស្រាវជ្រាវរយៈពេលច្រើនឆ្នាំស្តីពី ការអភិវឌ្ឍជំនាញ និងកំណែទម្រង់វិស័យអប់រំសម្រាប់ប្រទេសកម្ពុជាក្នុងឋានៈជាប្រទេសមានចំណូលកម្រិតមធ្យម" បើតាមការបញ្ជាក់របស់លោក ឡារី ស្រ្តែន្ទ នាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI ។

ឯកសារនេះលើកឡើងថា "សូចនាករច្បាស់លាស់ និងសំខាន់បំផុតមួយនៃ បញ្ហាកង្វះខាតគ្រូបង្រៀននៅកម្ពុជា គឺ អនុបាតសិស្ស-គ្រូ ដែលមានតួលេខខ្ពស់ណាស់នៅតាមសាលារៀន ជាពិសេសនៅកម្រិតបឋមសិក្សា"។ អនុបាតសិស្ស-គ្រូនៅតាមសាលាបឋមសិក្សានៅកម្ពុជា មានតួលេខខ្ពស់បំផុតក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន។ តួលេខនៃអនុបាតនេះគឺ ៤៦,២ ឬ ជិតដល់ ២ដង នៃតួលេខសម្រាប់ប្រទេសឡាវ (២៧) និង មីយ៉ាន់ម៉ា (២៨) និង ២,៥ដង នៃតួលេខសម្រាប់ប្រទេសវៀតណាម (២០)។ ឯកសារនេះបានកត់សម្គាល់ថា "អនុបាតសិស្ស-គ្រូ របស់កម្ពុជា មានតួលេខខ្ពស់ជាងគេទី១៦ នៅលើពិភពលោក និងខ្ពស់ជាងគេទាំងអស់ បើធៀបនឹងប្រទេសនានានៅក្រៅទ្វីបអាហ្វ្រិក"។

ក្រៅពីកង្វះចំនួនគ្រូបង្រៀន កង្វះខាតគ្រូដែលមានការបណ្តុះបណ្តាល និងគុណសម្បត្តិគ្រប់គ្រាន់ ក៏ហាក់ឃើញមានពាសពេញក្នុងប្រព័ន្ធអប់រំ និងនៅគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ដែលបានបន្ទាបនូវស្តង់ដារអប់រំរបស់ជាតិ ហើយនាំឲ្យមានកង្វះខាតគួរឲ្យកត់សំគាល់ក្នុងការរៀនសូត្ររបស់សិស្សានុសិស្ស។ បណ្ឌិត Srinivasa Madhur ប្រធានផ្នែកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI និងជាអ្នកនិពន្ធឯកសារនេះ សង្កត់ធ្ងន់ថា ប្រទេសកម្ពុជាត្រូវការនូវគ្រូបង្រៀនច្រើននាក់បន្ថែម និងមានគុណសម្បត្តិខ្ពស់ឡើងទៀត។

ឯកសារនេះ ស្នើដល់អ្នកធ្វើគោលនយោបាយឲ្យអនុវត្តយុទ្ធសាស្រ្តអភិវឌ្ឍគ្រូបង្រៀនមួយដែលមាន ៣ មុខព្រួញពាក់ព័ន្ធគ្នា៖ ការត្រៀមរៀបចំគ្រូបង្រៀនឲ្យបានល្អ (ការបណ្តុះបណ្តាលមុនពេលចូលបម្រើការងារ និងក្នុងពេលបំពេញការងារបានប្រសើរឡើង), ការផ្តល់បៀវត្សរ៍ឲ្យបានល្អដល់គ្រូបង្រៀន (កញ្ចប់លាភការប្រសើរឡើង) និង ការជំរុញគ្រូបង្រៀនឲ្យបំពេញការងារបានល្អ (ការបង្រៀន និងការរៀនសូត្ររបស់សិស្ស បានប្រសើរឡើង)។

ដើម្បីបង្កើនប្រសិទ្ធភាពនៃយុទ្ធសាស្រ្តអភិវឌ្ឍន៍គ្រូបង្រៀន សំដៅផ្តល់ការអប់រំប្រកបដោយគុណភាពនោះ ឯកសារនេះស្នើឡើងនូវវិធានការជាច្រើន មានជាអាទិ៍ ការត្រៀមរៀបចំកុមារឲ្យបានល្អតាំងពីក្មេងខ្ចី និងតាមការបង្រៀននៅថ្នាក់មតេយ្យសិក្សា, ការពិនិត្យឡើងវិញជាទៀងទាត់ និងធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា, ការកែលំអជាប់ជានិច្ចផ្នែកគរុកោសល្យ, ការចូលរួមរបស់សហគមន៍មូលដ្ឋាន ជាពិសេសពីសំណាក់មាតាបិតា ក្នុងការគ្រប់គ្រងសាលារៀន និង ការកែលំអ និងពង្រីកប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅកម្ពុជាដែលបច្ចុប្បន្ននៅមានលក្ខណៈដាច់ដោយដុំ។

ឯកសារនេះបានបូកសរុបដោយសង្កត់ធ្ងន់ថា ការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំខ្ពស់ៗបំផុតផ្នែកនយោបាយបាយ គឺជាលក្ខខណ្ឌដ៏ចាំបាច់ ដើម្បីឲ្យប្រទេសកម្ពុជាអាចកសាងបាននូវប្រព័ន្ធអប់រំទំនើបមួយ ដែលផ្តល់ឲ្យយុវជនកម្ពុជានូវ មូលដ្ឋានគ្រឹះសម្រាប់បន្តការសិក្សា និងការអភិវឌ្ឍជំនាញ។ ការកែសម្រួលខ្លះៗក្នុងគោលនយោបាយ មិនមែនជាដំណោះស្រាយទេ គឺត្រូវតែមានការពិនិត្យឡើងវិញជាទ្រង់ទ្រាយធំតែម្តង។ ក្នុងការគិតគូរឡើងវិញពីប្រព័ន្ធអប់រំនៅកម្ពុជា ការអនុវត្តកំណែទម្រង់នានាប្រកបដោយប្រសិទ្ធភាព និងការផ្លាស់ប្តូរស្របគ្នានៅក្នុងស្ថាប័ន គឺជាកត្តាសំខាន់បំផុត។ ចក្ខុវិស័យច្បាស់លាស់ និងការដឹកនាំរឹងមាំខាងផ្នែកអប់រំ គឺជាលក្ខខណ្ឌដ៏ចាំបាច់ដើម្បីសម្រេចគោលបំណងខាងលើ។

របាយការណ៍ពេញលេញជាភាសាអង់គ្លេស អាចរកបានតាមរយៈគេហទំព័ររបស់វិទ្យាស្ថាន CDRI៖ www.cdri.org.kh និង www.facebook.com/cdricambodia ។ អ្នកនិពន្ធអត្ថបទនេះ អាចទំនាក់ទំនងបានតាមទូរស័ព្ទលេខ ០២៣ ៨៨១៣៨៤ / ០២៣ ៨៨១៧០១ / ០១២ ៨៦៧២៧ ឬ ទូរសារ ០២៣ ៨៨០ ៧៣៤ ។